**គំរូ** ទំព័រនេះសម្រាប់សេចក្តីយោងតែប៉ុណ្ណោះ

ក្រសួងអភិវឌ្ឍន៍ការងារ
PO BOX 1234
ទីក្រុង គំរូ, CA 99999-9999

**លេខទូរស័ព្ទរបស់ EDD**

| | |
|---|---|
| អង់គ្លេស៖ | 1-800-300-5616 |
| អេស្ប៉ាញ៖ | 1-800-326-8937 |
| ចិនកាតាំង៖ | 1-800-547-3506 |
| ចិនកុកង៊ិ៖ | 1-866-303-0706 |
| វៀតណាម៖ | 1-800-547-2058 |
| TTY (គ្មានសម្លេង)៖ | 1-800-815-9387 |
| ទីតាំងអ៊ីនធឺណែត EDD៖ | edd.ca.gov |

គំរូ ឈ្មោះអតិថិជន
1234 គំរូ ST.
ទីក្រុងណាក៏ដោយ, CA 99999-9999

**កាលបរិច្ឆេទលិខិត៖** ខែ/ថ្ងៃ/ឆ្នាំ

## សេចក្តីជូនដំណឹងការទូទាត់មានលក្ខខណ្ឌផ្អែកទៅលើការត្រួតពិនិត្យ សិទ្ធិទទួល

សេចក្តីជូនដំណឹងនេះអនុវត្តទៅបញ្ហាចំពោះសិទ្ធិទទួលអាចកើតឡើង ណាមួយដែលកើតឡើងក្នុងបណ្តឹងទាមទាររបស់អ្នក។

យើងបានកំណត់ឃើញបញ្ហាអាចកើតឡើងជាមួយបណ្តឹងទាមទារ ដែល អាចធ្វើឲ្យអ្នកមិនមានសិទ្ធិសម្រាប់អត្ថប្រយោជន៍។ ដោយសារតែអ្នកបានទទួលអត្ថប្រយោជន៍រួចហើយលើការទាមទារភាពអត់ការងារធ្វើរបស់អ្នក យើងកំពុងដំណើរការសប្តាហ៍ដែលមិនទាន់សម្រេចរបស់អ្នកសម្រាប់ការទូទាត់តាមលក្ខខណ្ឌ ខណៈពេលដែលយើង កំណត់សិទ្ធិបន្តរបស់អ្នក។ ប្រសិនបើអ្នកបន្តបញ្ជាក់សម្រាប់អត្ថប្រយោជន៍ ខណៈពេលដែលយើងកំពុងកំណត់សិទ្ធិរបស់អ្នក ការទូទាត់តាមលក្ខខណ្ឌណាមួយនឹងត្រូវបានចាត់ទុកថាជាការបង់ប្រាក់លើស ប្រសិនបើយើងរកឃើញថាអ្នកមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍ទាំងនោះនៅពេលក្រោយ។

យើងនៅតែសម្រេចសិទ្ធិទទួលរបស់អ្នកចំពោះបញ្ហាកំពុងកើតឡើង ដែលនឹងនាំឆ្ពោះទៅលទ្ធផលមួយនៃលទ្ធផលទាំងនេះ៖

- អ្នកនឹងទទួលការទូទាត់ជាប់លក្ខខណ្ឌ ហើយក្រោយមកត្រូវបានរក ឃើញថាមានសិទ្ធិទទួលទាំងនោះ។
- អ្នកនឹងទទួលការទូទាត់ជាប់លក្ខខណ្ឌ ហើយក្រោយមកត្រូវបានរក ឃើញថាមិនមានសិទ្ធិទទួលទាំងនោះ។ ប្រសិនបើអ្នកមិនមានសិទ្ធិ យើងនឹងផ្ញើរដល់អ្នកនូវ *សេចក្តីជូន ដំណឹងចំពោះការសម្រេច* ដែលអ្នកអាចប្តឹងឧទ្ធរណ៍។ អ្នកប្រហែលជាត្រូវសងប្រាក់វិញតាមលក្ខខណ្ឌដែលទទួលបាន ប្រសិនបើអ្នកមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការលើកលែងការបង់ប្រាក់លើស។

ក្នុងអំឡុងការត្រួតពិនិត្យអ្នកមិនអាំចទទួលការទូទាត់ ប្រសិនបើអ្នក៖

- មានការងារពេញលេញ ឬបានរាយការណ៍នូវប្រាក់ចំណូលច្រើនលើសលប់។
- កំពុងបម្រើការពិន័យលើសេចក្តីថ្លែងការមិនពិតពីមុន។
- មានកង្វះលក្ខណៈសម្បត្តិរួចជាស្រាច់។
- មានការទូទាត់លើសពីមុន ហើយអត្ថប្រយោជន៍របស់អ្នកត្រូវបានអនុវត្តចំពោះការទូទាត់លើស។

ការជូនដំណឹងនេះត្រូវបានអនុវត្តនៅពេលដែលយើងមិនអាចធ្វើការសម្រេចក្នុងរយៈពេលពីរសប្តាហ៍នៃពេលដែលយើងបានកំណត់បញ្ហានៃ សិទ្ធិទទួលបានសក្តានុពល។

**តើអ្វីត្រូវរំពឹងទុក**

ខណៈពេលដែលយើងកំណត់សិទ្ធិរបស់អ្នក សូមបន្តការបញ្ជាក់អំពីអត្ថប្រយោជន៍ ប្រសិនបើអ្នកបន្តគ្មានការងារធ្វើ ឬកំពុងធ្វើការកាត់បន្ថយម៉ោងធ្វើការ ។ របៀបលឿនបំផុតដើម្បីបញ្ជាក់តាមរយៈ UI Online[SM] គឺដោយចូលទៅ portal.edd.ca.gov ។ យើងនឹងបន្តទូទាត់ដល់អ្នកដរាបណាអ្នកបន្តបញ្ជាក់លើកលែងតែយើងរកឃើញថាអ្នកគ្មានសិទ្ធិទទួលទៀត។

**អ្នកមិនគួរបន្តការបញ្ជាក់ប្រសិនបើអ្នកមានការងារពេញលេញ ឬបើមិនដូច្នេះទេជឿថាអ្នកមិនមានសិទ្ធិទទួលបានអត្ថប្រយោជន៍។**

យើងអាចទាក់ទងអ្នក ប្រសិនបើយើងត្រូវការព័ត៌មានបន្ថែម ដើម្បីកំណត់សិទ្ធិរបស់អ្នក។ វាសំខាន់ណាស់ដែលអ្នកឆ្លើយតបនឹងយើង។ រសិនបើអ្នកមិនឆ្លើយតបតាមការស្នើសុំទេ យើងនៅតែត្រូវធ្វើការសម្រេចចិត្តដោយផ្អែកលើព័ត៌មានដែលមានសម្រាប់យើង។ ដោយគ្មានព័ត៌មានពីអ្នកយើងអាចរកឃើញថាអ្នកគ្មានសិទ្ធិសម្រាប់ការទូទាត់មានលក្ខខណ្ឌអ្នកបានទទួល។ សម្រាប់ព័ត៌មានបន្ថែម ស្តីពីបញ្ហាខាងសិទ្ធិទទួល សូមចូលទៅ edd.ca.gov/en/claim-status ។

**ក្រោយពីយើងកំណត់សិទ្ធិទទួល**

ដើម្បីមានសិទ្ធិទទួលបានអត្ថប្រយោជន៍ អ្នកត្រូវតែបំពេញតាមលក្ខខណ្ឌមានសិទ្ធិទទួលបានសម្រាប់ភាពអត់ការងារធ្វើជារៀងរាល់សប្តាហ៍។

ប្រសិនបើយើងបញ្ជាក់សិទ្ធិទទួលរបស់អ្នកអ្នកមិនចាំបាច់ធ្វើអ្វីឡើយក្រោមពីសប្តាហ៍ទាំងឡាយបានទទួលការទូទាត់។ បន្តបញ្ជាក់សម្រាប់អត្ថប្រយោជន៍រៀងរាល់ពីរសប្តាហ៍ ប្រសិនបើអ្នកនៅតែគ្មានការងារ ឬកំពុងតែធ្វើការ ចំនួនម៉ោងកាត់បន្ថយ។ សម្រាប់ជំនួយឆ្លើយនឹងសំណួរស្តីពីការបញ្ជាក់ សូមចូលទៅ edd.ca.gov/en/Unemployment/Understanding_the_Continued_Claim_Certification_Questions.

ប្រសិនបើអ្នកមិនសមស្របនឹងតម្រូវការសិទ្ធិទទួល យើងនឹងផ្ញើរដល់អ្នកនូវ *សេចក្តីជូនដំណឹងចំពោះការសម្រេច* (DE 1080CZ) ដែលអ្នកអាចប្តឹងឧទ្ធរណ៍។ អ្នកក៏ប្រហែលជាត្រូវសងប្រាក់វិញ ដែលទទួលបានប្រសិនបើអ្នក មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការលើកលែងការបង់ប្រាក់លើស។ យើងអាចផ្ញើរដល់អ្នកនូវ *សេចក្តីជូនដំណឹងការទូទាត់លើសដែលអាចកើតឡើង* (DE1447) និង/ឬ កសេចក្តីជូនដំណឹងនៃការទូទាត់លើស (DE1444)។ អ្នកនឹងមានសិទ្ធិប្តឹងឧទ្ធរណ៍លើការសម្រេចចិត្តនេះ និងការទូទាត់លើស ហើយត្រូវបានពិចារណាឡើងវិញសម្រាប់ការលើកលែងការទូទាត់លើស។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅ edd.ca.gov/en/claims/Benefit-Overpayments ។